# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ អំពីអរិយធម៌ វប្បធម៌ និងសង្គមធម៌

Website: www.hoksavann.org

ថ្ងៃទី១៨ វិច្ឆិកា ២០០៤

### អំពីពាក្យអរិយធម៌

ពាក្យថាអរិយធម៌ ប្រែថាធម៌ឬសភាពប្រសើរខ្ពង់ខ្ពស់ ថ្លៃថ្នូរ រុងរឿង ។ បានដល់ការរស់នៅប្រសើរ គឺការរៀបចំជីវភាពប្រកបដោយសេចក្តីសុខចំរើនក្នុងសង្គមមនុស្ស ។ អរិយធម៌សំគាល់នូវការចំរើនលូតលាស់នៃមនុស្សជាតិ ។ គ្រប់ជនជាតិទាំងអស់សុទ្ធតែមានអរិយធម៌រៀងៗខ្លួន ប្លែកតែត្រង់អរិយធម៌នៃជនជាតិខ្លះបានចំរើនលូតលាស់ អរិយធម៌នៃជនជាតិខ្លះនៅទន់ខ្សោយប៉ុណ្ណោះ ។ អរិយធម៌នេះហើយដែលចែកចេញជាវប្បធម៌និងសង្គមធម៌ ។

វប្បធម៌ = វប្បធម៌គឺធម៌ឬសភាពដែលបណ្តុះបណ្តាលឲ្យចំរើនលូតលាស់ខាងចំណេះវិជ្ជា ចិត្តគំនិត សីលធម៌ ដូចជាជំនឿសាសនា ភាសា អក្សរ ការសិក្សាអប់រំ អក្សរសាស្ត្រ សិល្បៈ ទំនៀមទំលាប់ ប្រពៃណីជាដើម ។

សង្គមធម៌ = សង្គមធម៌បានដល់ការចំរើនលូតលាស់ខាងសម្ភារៈដូចជាទីលំនៅ ប្រដាប់ប្រដាប្រើប្រាស់ ចំណីអាហារបរិភោគ សំលៀកបំពាក់ ថ្នាំកែរោគ ប្រដាប់បច្ចេកទេស សេដ្ឋកិច្ចជាដើម ។

អំពីទំនាក់ទំនងរវាងវប្បធម៌និងសង្គមធម៌ = វប្បធម៌និងសង្គមធម៌ត្រូវមានទំនាក់ទំនងគ្នាជាដរាប ទើបធ្វើឲ្យសង្គមបានសុខសន្តិភាពនិងចំរើនលូតលាស់ ។ បើវប្បធម៌បានចំរើន មនុស្សមានចំណេះចេះដឹង ចេះគិតគូរពិចារណា បង្កើតសម្ភារៈគ្រប់យ៉ាង សំរួលដល់ការរស់នៅរបស់សង្គមមនុស្សឲ្យកាន់តែប្រសើរឡើង ។ នយោបាយក៏ចាត់ចូលក្នុងផ្នែកវប្បធម៌ គឺបើវប្បធម៌បានចាក់គ្រឹះយ៉ាងមាំ បណ្តុះគំនិតជាតិនិយមឲ្យបានខ្លាំងក្លា ផ្លូវនយោបាយក៏មានថាមពលខ្លាំងដែរ ។ បើសង្គមធម៌បានចំរើនលូតលាស់ខាងសម្ភារៈ គេអាចយកជាឧបករណ៍សំរាប់ប្រើប្រាស់ក្នុងការសិក្សាអប់រំ និងធ្វើការពិសោធន៍រកបច្ចេកទេសថ្មីៗទៀត ។ គេអាចយកបច្ចេកទេសទំនើបទៅប្រើប្រាស់ ក្នុងផ្សព្វផ្សាយទេសនាសិល្បៈវប្បធម៌ ដែលបណ្តុះនូវគំនិតប្រាជ្ញាស្មារតីនិងសីលធម៌ ឲ្យកើតកាន់តែរហ័សឡើង ដូចជាមធ្យោបាយផ្សាយតាមវិទ្យុទូរទស្សន៍ សៀវភៅ ទស្សនាវដ្តីភាពយន្តជាដើម ។ ដូច្នេះវប្បធម៌និងសង្គមធម៌ត្រូវមានទំនាក់ទំនងគ្នាទៅវិញទៅមក គឺវប្បធម៌ផ្តល់សេចក្តីសុខឲ្យដល់សង្គមមនុស្សតាមផ្លូវចិត្ត និងជាគ្រឿងបំភ្លឺដល់ការស្វែងរកផ្លូវសម្ភារៈ ឯសង្គមធម៌ផ្តល់សេចក្តីសុខឲ្យដល់សង្គមមនុស្សតាមផ្លូវសម្ភារៈ ។ បើចំរើនតែម្ខាងខ្លាំងពេកនឹងមានគ្រោះថ្នាក់ដល់សង្គមមនុស្ស ដូចជាសម្ភារៈលឿនខ្លាំង ចំណែកផ្លូវសីលធម៌ពុំសូវចំរើន សង្គមមនុស្សនឹងបៀតបៀនគ្នារំលោភលើគ្នា និងធ្វើឲ្យពិភពលោកមានដំណើរឆ្ពោះទៅរកចំបាំង ដែលផ្ទុយពីពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ដែលព្រះអង្គត្រាស់ថា សេចក្តីសុខសន្តិភាពកើតឡើងពីចិត្តស្ងប់ពុំបៀតបៀនគ្នា ។ វិទ្យាសាស្ត្រមួយផ្នែកចំរើនឡើងដើម្បីធ្វើសង្គមមនុស្សបានសុខដូចជាការលូតលាស់ខាងទីលំនៅ ប្រដាប់ប្រដាប្រើប្រាស់ បច្ចេកទេសពេទ្យ យន្តយានគ្រប់ប្រភេទសំរាប់ធ្វើដំណើរជាដើម ។ ប៉ុន្តែការចំរើនលូតលាស់របស់វិទ្យាសាស្ត្រមួយផ្នែកទៀតគឺធ្វើឲ្យលោកវិនាស ដូចជាការបង្កើតសាស្ត្រាវុធគ្រប់បែប ការបង្កើតគ្រាប់មីនកប់ក្នុងដី រហូតបង្កើតគ្រាប់បែកបរមាណូនៃប្រទេសខ្លះ បើគ្មានវប្បធម៌ជាផ្នែកសីលធម៌ជួយទប់ទេ នឹងយកទៅប្រើធ្វើឲ្យលោកវិនាស ។

### អំពីវិសេសភាពនៃវប្បធម៌ខ្មែរ

វប្បធម៌ខ្មែរមានវិសេសភាពរបស់ខ្លួនតាំងពីបូរាណមក ទោះបីផ្នែកខ្លះបានយកពីវប្បធម៌ឥណ្ឌាក៏ដោយ ប៉ុន្តែបានយកមកឆ្នៃរចនាឲ្យមានលក្ខណៈជាខ្មែរទាំងអស់ ។ ខ្មែរមានវិចារណញ្ញាណជឿកម្មផលជឿហេតុល្អហេតុអាក្រក់ ពេលព្រះពុទ្ធសាសនាចូលមកមានលក្ខណៈ ដូចជាអត្តសញ្ញាណរបស់ខ្លួន ខ្មែរក៏ទទួលយកភ្លាម ។ អក្សរសិល្ប៍រឿងរាមកេរ្តិ៍ខ្មែរ ដែលដកស្រង់ចេញពីរឿងរាមាយនៈឥណ្ឌា ដែលលើកតម្កើងព្រះរាមជាតួអង្គអាទិទេពនោះ ក្នុងរាមកេរ្តិ៍ខ្មែរបានទាញព្រះរាមទៅជាមនុស្សសាមញ្ញធម្មតា ចេះយំចេះសោក មានការព្រាត់ប្រាសគ្នា រហូតព្រះរាមចូលកោដិបញ្ឆោតនាងសីតា ។ សិល្បៈក្បាច់ក្បូរផ្សេងៗមានលក្ខណៈខុសគ្នាពីសិល្បៈឥណ្ឌា ដូចជាប្រាសាទអង្គរវត្តជារចនាបថរបស់ខ្មែរសុទ្ធសាធ ។ ផ្នែករបាំក៏ដូចគ្នា របាំឥណ្ឌាកាយវិការរាំមានចលនាទាំងដៃទាំងជើងទាំងដងខ្លួន ទាំងក្បាល ដែលមានលក្ខណៈផ្ទុយគ្នាពីរបាំខ្មែរ ដែលប្រើកាយវិការតែដៃនិងជើង ឯដងខ្លួននៅត្រង់ជានិច្ច សូម្បីថៃខំចម្លងធ្វើតាមក៏មិនដូចខ្មែរដែរ ។ ភាសាខ្មែរមិនប្រើវិភត្តិ ហើយពុំមានសម្លេងឡើងចុះទៅតាមសញ្ញាដាក់ពីលើពាក្យដែលនាំឲ្យដូរន័យទេ ។ ខ្មែរមានភាសាខ្មែរសុទ្ធរួចមកហើយ ក្រោយមកទើបមានខ្ចីពាក្យខ្លះពីភាសាបាលីនិងសំស្ក្រឹត ប៉ុន្តែយកមកឆ្នៃឲ្យទៅជាភាសានិងសម្លេងខ្មែរដោយលុបវិភត្តិចោល ។ ចំណែកអក្សរខ្មែរដែលមានរូបរាងសមរម្យដូចសព្វថ្ងៃនេះ បានត្រូវកែសម្រួលជាង១០ដងរួចមកហើយ ។ ដូច្នេះខ្មែរមានវប្បធម៌របស់ខ្លួនពិតប្រាកដរួចមកហើយ ទើបមានវប្បធម៌ដទៃចូលមកជាក្រោយ ប៉ុន្តែបានឆ្នៃធ្វើជាតួបនីយកម្មឲ្យស្របតាមលក្ខណៈរបស់ខ្លួន ។ លោក B.P. Groshier និងលោក Maurice Glaïze បានបញ្ជាក់ថា ជនជាតិខ្មែរមានអរិយធម៌របស់ខ្លួនមុនរួចស្រេចទៅហើយ ទើបមានឥទ្ធិពលឥណ្ឌាជាក្រោយ ។ អក្សរសិល្ប៍ខ្មែរ ទោះបីរឿងខ្លះយកសត្វធ្វើជាតួអង្គក៏ដោយ ក៏មានន័យតំណាងសង្គមមនុស្ស ទុកជាកញ្ចក់សំរាប់ឆ្លុះមើលព្រឹត្តិការណ៍ក្នុងសម័យកាលនីមួយៗ ។ មូលដ្ឋានរបស់វប្បធម៌ខ្មែរគឺព្រះពុទ្ធសាសនាថេរវាទ ដែលរក្សាទុកនូវព្រះពុទ្ធដីកាមិនកែប្រែជាសាសនាស្របតាមចិត្តគំនិតខ្មែរ ។ ដូច្នេះខ្មែរមានឯកភាពខាងភាសា ឯកភាពខាងអក្សរ ឯកភាពខាងសាសនា ហើយទឹកដីខ្មែរសំបូរសម្បត្តិធម្មជាតិ ដែលអាចឆ្នៃឲ្យប្រទេសចំរើនលូតលាស់បាន គួរខ្មែរគ្រប់រូបនាំគ្នារក្សាមរតកដ៏មានតម្លៃរបស់ដូនតានេះឲ្យគង់វង់កុំឲ្យបាត់បង់ ។៚